ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ៩២៣/០៥-១១-២០១០

**សាលដីកា**

លេខ០២ក្រVIយ

ចុះថ្ងៃទី០៨-០១-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី២៤-១២-២០១៣ដែលមានសមាសភាពដូចតទៅៈ

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក [redacted] ប្រធាន**

**លោក [redacted] ចៅក្រមប្រឹក្សា**

**លោក [redacted] ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក [redacted]**

**ក្រឡាបញ្ជី**

**លោកស្រី [redacted]**

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ៩២៣ចុះថ្ងៃទី០៥-១១-២០១០រវាងៈ

**-ជនជាប់ចោទឈ្មោះ**NWATU [redacted]**(ដើមបណ្តឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៥ឆ្នាំ ជាតិ<u>នីហ្សេរីយ៉ា</u> កើតនៅរដ្ឋ[redacted] មានទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](ស)នៅលីវ។ទោសពីមុនគ្មាន ។<u>ឃុំខ្លួនថ្ងៃទី០៥.៣.២០១០</u>។**មានមេធាវី** [redacted] **សារុទ្ធី**.

ជាប់ចោទពីបទប្លន់.បទធ្វើឲ្យខូចខាតដោយចេតនា និងបទចូលមកព្រះរាជាណាចក្រកម្ពុជា



២៤០

ដោយគ្មានច្បាប់អនុញ្ញាត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១-៣-២០១០ បទល្មើសដែល ចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ មាត្រា៥២នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល តាមមាត្រា២៩នៃច្បាប់ស្តីពីអន្តោប្រវេសន៍។

**-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] **(ចុងបណ្តឹងឧទ្ធរណ៍** ភេទប្រុស ទីលំនៅសព្វថ្ងៃ [redacted]។

**ថ្មានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-៨-២០១០របស់លោក [redacted] សាវុឌ្ឍី ជាមេធាវី ទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ NWATU [redacted] មិនសុខចិត្តនឹងសាល ក្រមព្រហ្មទណ្ឌលេខ៩០ក្រ២យ/២៥-៨-២០១០សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តី សំរេចទាំងមូល។

**<u>៦ដំណើររឿងមានដូចតទៅ៖</u>**

កាលពីថ្ងៃទី០១-៣-២០១០វេលាម៉ោង១០ម៉០០នាទីព្រឹក ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស និង ឈ្មោះPETERបានទូរស័ព្ទទៅឈ្មោះ NNARAH [redacted] ឲ្យមកជួប នៅផ្ទះឈ្មោះ UGOCHUKWU [redacted] ស្ថិតនៅផ្ទះជួលលេខ៣២EO ផ្លូវលេខ បេតុង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។លុះដល់ពេលជនរងគ្រោះ និង មិត្ត ភ័ក្តឈ្មោះ UGOCHUKWU [redacted]មកដល់ ជនត្រូវចោទឈ្មោះ [redacted] និង ឈ្មោះPETERបានគំរាមទារប្រាក់ពីឈ្មោះNNARAH [redacted] តែឈ្មោះនេះមិន ព្រមឲ្យ ជនត្រូវចោទឈ្មោះ [redacted] បានស្ទុះចូលទៅយកកាំបិតប៉័ងតោមកកាប់ឈ្មោះ NNARAH [redacted]ចំនួន២កាំបិត បណ្តាលឲ្យរងរបួស ជនត្រូវចោទក៏រត់គេចខ្លួន។ ដោយជនរងគ្រោះមានរបួស មិត្តភ័ក្តជនរងគ្រោះបានដឹកមកគ្លីនីក លុះមកដល់ចំណុចវត្តស្វាយ ពពៃ ទល់មុខស្ពានទូតរុស្ស៊ី ស្រាប់តែជនត្រូវចោទឈ្មោះ NWATU [redacted] ដែលជាបក្ខពួករបស់ជនត្រូវចោទខាងលើ បានឃាត់ឡានឲ្យឈប់ រួចបានវាយជនរងគ្រោះ ឈ្មោះNNARAH [redacted] យកប្រាក់ និង ទូរស័ព្ទដៃរួចរត់គេចខ្លួនតែម្តង។ដល់ថ្ងៃទី ០២-៣-២០១០សមត្ថកិច្ចបានធ្វើការស្រាវជ្រាវឃាត់ខ្លួនជនត្រូវចោទឈ្មោះ NWATU [redacted] តែម្តង។តាមរបាយការណ៍របស់សមត្ថកិច្ចបានបញ្ជាក់ថា ជនត្រូវចោទឈ្មោះ NWATU [redacted]បានបំផ្លាញរថយន្ត.គុ កៅអី របស់សមត្ថកិច្ច និង បានចូល មករស់នៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ ព្រមទាំងប្រើប្រាស់គ្រឿងញៀនទៀតផង។

**ថ្មានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ៩០ក្រ២យ/២៥-៨-២០១០សាលាដំបូងរាជធានី ភ្នំពេញសំរេចសេចក្តីដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះNWATU CHALES [redacted]ភេទប្រុស អាយុ ២៥ឆ្នាំ ជនជាតិ

នីហ្សេរីយ៉ា ដាក់ពន្ធនាគារកំណត់៦(ប្រាំមួយឆ្នាំ)ឆ្នាំ។

ពីបទប្លន់.បទធ្វើឲ្យខូចខាតដោយចេតនា . បទប្រើប្រាស់គ្រឿងញៀន និង បទចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានច្បាប់អនុញ្ញាត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១-៣-២០១០ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ មាត្រា៥២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តាមមាត្រា២៩នៃច្បាប់ស្តីពីអន្តោប្រវេស្ត និង មាត្រា៩៨ថ្មីនៃច្បាប់វិសោធនកម្មស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បង្គាប់ឲ្យឈ្មោះNWATU [redacted]សងជំងឺចិត្ត១.៥០០.០០០៛(មួយលានប្រាំសែនរៀល)ឲ្យទៅឈ្មោះNNARAH [redacted] ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិនីហ្សេរីយ៉ា ជាភាគីដើមបណ្តឹង។ដើមបណ្តឹងទារលើសពីនេះបដិសេធចោល។តាមមាត្រា៣៥៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បណ្តេញចេញនូវឈ្មោះNWATU [redacted]ពីព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីទទួលអនុវត្តទោសជាស្ថាពរហើយ។តាមមាត្រា៦១នៃក្រមព្រហ្មទណ្ឌ។

៤-សាលក្រមនេះជំនុំជំរះនាថ្ងៃទី០២-៨-២០១០ និង ប្រកាសជាសាធារណៈនាថ្ងៃទី១២-៨-២០១០ ចំពោះមុខជនជាប់ចោទឈ្មោះNWATU [redacted] និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះNNARAH[redacted]។

ទុកសិទ្ធប្តឹងទាស់ និង ឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ឲ្យានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-៨-២០១០របស់លោកទិត សាវុឌ្ឍី ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ NWATU [redacted]មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩០ក្រ២យ/២៤-៨-២០១០សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសំរេចទាំងមូល។

បានឃើញរបាយការណ៍របស់សាលាឧទ្ធរណ៍.

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការសាលាឧទ្ធរណ៍។

## <u>នាពេលសវនាការ</u>

ចៅក្រមអានរបាយការណ៍.

*អ្នកបកប្រែឈ្មោះសុទ្ធ សាងបុណ្យ៖*ខ្លួនជាអ្នកបកប្រែ មានឈ្មោះសុទ្ធ សាងបុណ្យ មានលេខទូរស័ព្ទ០១២ ៣០៣១៦៩ មានអាស័យដ្ឋានផ្ទះលេខ០៤អា ផ្លូវលេខ២០២ សង្កាត់ដើមមានក្រុងតាខ្មៅ ខេត្តកណ្តាល។

*ជនជាប់ចោទឈ្មោះNWATU* [redacted]*ឆ្លើយថា៖*ខ្លួនមានអាយុ២៥ឆ្នាំ ជាតិនីហ្សេរីយ៉ា កើតនៅ[redacted] មានទីលំនៅសព្វថ្ងៃ[redacted] ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ[redacted] (ស)នៅលីវ។ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី០៥-៣-២០១០។មានមេធាវី [redacted] សាវុឌ្ឍី។ខ្លួនយល់ព្រមទទួលអ្នកបកប្រែ និង មេធាវីខ្លួនប្តឹងឧទ្ធរណ៍

មិនសុខចិត្តត្រង់ចំណុចទាំងមូល ព្រោះខ្លួនមិនបានប្រព្រឹត្តអំពើប្លន់អ្វីទេ ខ្លួនមិនសុខចិត្តត្រង់ចំណុចដាក់ទោសខ្លួនច្រើនពេករហូតដល់ទៅ០៦ឆ្នាំ និង សុំកុំឲ្យបញ្ជូនខ្លួនទៅប្រទេសខ្លួនវិញអី។កាលពីខ្លួននៅប្រទេសខ្លួនៗមិនដែលមានទោសទេ។ខ្លួនចេញពីប្រទេសខ្លួនដំបូងមកប្រទេសវៀតណាម តាមច្បាប់ត្រឹមត្រូវ។កាលពីឆ្នាំ២០១០ប្រទេសវៀតណាមគេមិនត្រូវការជនជាតិស្បែកខ្មៅដូចខ្លួនទេ ខ្លួនក៏ចូលមកប្រទេសកម្ពុជាតាមច្រកមិនស្គាល់ ខ្លួនជិះរថយន្តក្រុង។ខ្លួននៅប្រទេសវៀតណាមចំនួន១ឆ្នាំ៨ខែ ខ្លួនចូលមកប្រទេសកម្ពុជានៅចុងឆ្នាំ២០០៩ ខ្លួនឲ្យលុយគេៗជួយខ្លួនឲ្យមកប្រទេសកម្ពុជា ឬថៃក៏បាន។នៅថ្ងៃកើតហេតុខ្លួនមិនបានប្លន់ និង ប្រើគ្រឿងញៀនទេ។ឈ្មោះADIBE FRANCIS គាត់ជំពាក់លុយខ្លួនចំនួន២០០០$ ឯឈ្មោះណារីក្វ ខ្លួនមិនស្គាល់ទេ។ដំបូងខ្លួនមកប្រទេសកម្ពុជា ជួបឈ្មោះADIBE FRANCIS ជាអ្នកជួយខ្លួនដើម្បីបើកក្រុមហ៊ុនបន្ទាប់មកគាត់គេចខ្លួន។ក្រោយមកខ្លួនជួបឈ្មោះADIBE FRANCISដោយចៃដន្យ ខ្លួនសុំឲ្យគាត់សងលុយវិញ តែគាត់ថាគ្មានលុយសងទេ តែគាត់បានឲ្យរបស់បញ្ចាំមានឡេបថប និង ទូរស័ព្ទ។ខ្លួនស្គាល់ADIBE FRANCIS នៅប្រទេសវៀតណាម ខ្លួនមិនស្គាល់ណារីក្វទេ ខ្លួនមិនដែលមានទំនាស់ជាមួយឈ្មោះណារីក្វទេ។ខ្លួនមិនបានឃាត់ឡានជនរងគ្រោះទេ។ខ្លួនមិនមានលិខិតឆ្លងដែនទេ មិត្តស្រីខ្លួនបានដកទុកហើយ មិត្តស្រីខ្លួននៅប្រទេសវៀតណាម ហើយខ្លួនមានកូនស្រីម្នាក់នៅវៀតណាម សុំកុំបញ្ជូនខ្លួនទៅប្រទេសខ្លួនវិញអី។ពេលខ្លួនចេញមកពីប្រទេសវៀតណាមខ្លួនមានបញ្ហាក្រលៀន មិត្តស្រីខ្លួនបានផ្ញើថ្នាំវិតាមីនបេ១២ និង ថ្នាំកំលាំងផ្សេងៗទៀត តែខ្លួនមិនស្គាល់ទេ។ខ្លួនមិនដែល បានស្ទាក់ឡានដើមបណ្ដឹងទេ ។ប៉ូលីសបានចាប់ខ្លួនដល់ផ្ទះ ពេលខ្លួននៅក្នុងបន្ទប់ទឹកកំពុងងុសធ្មេញ ខ្លួនមិនបានប្រតាយប្រតប់ជាមួយប៉ូលីស និង ធ្វើឲ្យខូចខាតសំភារៈរបស់ប៉ូលីសទេ។ប៉ូលីសសរសេរដាក់ថាខ្លួនមានថ្នាំញៀន ហើយប៉ូលីសបង្ខំឲ្យខ្លួនផ្ដិតមេដៃទៀត តែតាមពិតជាថ្នាំដែលប្រពន្ធខ្លួនផ្ញើឲ្យ។ពេលខ្លួនឆ្លើយនៅមុខប៉ូលីស គ្មានអ្នកបកប្រែទេ តែមានប៉ូលីសឈ្មោះសារឿន ចេះនិយាយភាសាអង់គ្លេសតិចៗ ពេលឆ្លើយរួច ប៉ូលីសមិនបានអានឲ្យខ្លួនស្ដាប់ឡើងវិញទេ។សំណូមពរ ខ្លួនពិតជាបានចូលមកកម្ពុជាគ្មានលិខិតឆ្លងដែនមែន សុំកុំបញ្ជូនខ្លួនទៅប្រទេសខ្លួនវិញអី សុំបន្ថយទោសខ្លួនឲ្យបានទាប ព្រោះខ្លួនមិនមានថ្នាំញៀន និង មិនបានប្លន់គេទេ ខ្លួនមិនបានធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់គេទេ សុំសិទ្ធិមានសេរីភាពវិញ។

*ក្រឡាបញ្ជីអានចំលើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ NNARAH* [redacted]

*តំណាងមហាអយ្យការសន្និដ្ឋានថា៖*

-សុំពិនិត្យអង្គហេតុទាំង២រឿងឡើងវិញ អង្គហេតុទាំង២នេះមិនមានលក្ខណៈជាបទល្មើសធំដុំទេ ជាបទល្មើសតូចតាច ដែលបំបែកអង្គហេតុតែ១ទៅជា២សំណុំរឿង ដោយផ្ដន្ទាទោសចំនួន០៥ឆ្នាំ និង ចំនួន០៦ឆ្នាំ សុំពិចារណាតាមតាមមាត្រា៥០១នៃនីតិវិធីព្រហ្មទណ្ឌ មាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ និង បណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជា។

*មេធាវី* [redacted] *ហេង និង* [redacted] *សាវុឌ្ឍី សន្និដ្ឋានថា៖*ខ្លួនជាមេធាវីការពារឲ្យឈ្មោះNWATU [redacted] ។រឿងនេះកូនក្ដីខ្លួនបដិសេធគ្រប់ដំណាក់កាល ទាំងនៅមុខប៉ូលីស

នៅមុខអយ្យការ និង នៅមុខចៅក្រមស៊ើបសួរ ។រឿងនេះមិនមានភស្តុតាងដាក់បន្ទុកកូនក្តីខ្លួនពីបទប្លន់ទេ កូនក្តីខ្លួនពិតជាបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានលិខិតឆ្លងដែនមែន ចំពោះថ្នាំញៀន ការបំផ្លាញទ្រព្យសម្បត្តិរបស់ប៉ូលីសមិនមានទេ សំណូមពរសុំលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួន សុំដោះលែងកូនក្តីខ្លួនឲ្យមានសេរីភាព សុំកុំបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា ព្រោះកូនក្តីខ្លួនមានប្រពន្ធព្រមទាំងកូនហើយ សុំស្រ្ទបទោស ។

ក្រោយពីបានស្តាប់ចំលើយជនជាប់ចោទ.

ក្រោយពីបានស្តាប់អំណានចំលើយដើមបណ្តឹងរដ្ឋប្បវេណី.

ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន.

ក្រោយពីបានស្តាប់មេធាវីសន្និដ្ឋានការពារ.

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-៨-២០១០របស់លោកទិត សាវុឌ្ឍី ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ NWATU [redacted] មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៩០ក្រ២ឃ/២៤-៨-២០១០សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់យោងមាត្រា៣៨២នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

២-តាមចំលើយរបស់ជនជាប់ចោទឈ្មោះNWATU [redacted] បានឆ្លើយបដិសេធនូវអំពើប្រព្រឹត្តរបស់ខ្លួន ប៉ុន្តែឈ្មោះនេះទទួលស្គាល់ថា ខ្លួនពិតជាបានចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់មែន។

៣-តាមចំលើយរបស់ឈ្មោះADIBE FRANCISបានបញ្ជាក់ថា កាលពីថ្ងៃទី០១-៣-២០១០ខ្លួន និង មិត្តភ័ក្តត្រូវបានឈ្មោះNWATU [redacted] និង ក្មេងប្រុស៤នាក់គំរាមទារប្រាក់ពីខ្លួន ពេលនោះគ្មានប្រាក់ឲ្យ គេយកទូរស័ព្ទ និង កាបូបរបស់ខ្លួន គឺមានប្រាក់២០០$ និង ទូរស័ព្ទ៣គ្រឿងរត់គេចខ្លួនបាត់។

៤-តាមចំលើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានបញ្ជាក់ថា កាលពីថ្ងៃទី០១-៣-២០១០ឈ្មោះOMENIFEបានទូរស័ព្ទឲ្យខ្លួនទៅជួបបម្ពុំស្ទឹងមានជ័យ ខ្លួនក៏ចេញទៅជួបឈ្មោះONYEDA ពេលទៅដល់ផ្ទះជួលក៏ឃើញឈ្មោះOMENIFE និង ឈ្មោះPETERគំរាមទារប្រាក់ពីខ្លួនចំនួន២០០០$មុនបើកហាងលក់ដូរ ពួកខ្លួនពុំព្រមឲ្យ ឈ្មោះOMENIFEបានស្ទុះទៅយកកាំបិតកាប់ពួកខ្លួនៗក៏ឡើងជិះឡានរត់ដល់ចំណុចវត្តស្វាយពពែទល់មុខស្ថានទូតរុស្ស៊ី ស្រាប់តែឈ្មោះNNARAH [redacted] ដែលជាបក្សពួករបស់អ្នកទាំង២បានឃាត់ឡានរបស់ខ្លួនទារប្រាក់ និង យកទូរស័ព្ទដៃរត់គេចខ្លួនបាត់។

៥-តាមអង្គហេតុ និង តាមការឆ្លើយរបស់ជនជាប់ចោទឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ថាជនជាប់ចោទរូបនេះបានប្រព្រឹត្តបទល្មើសប្រើប្រាស់គ្រឿងញៀនឡើយ ប៉ុន្តែទោះបីជនជាប់ចោទរូបនេះបានបដិសេធថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសប្លន់ ធ្វើឲ្យខូចខាតដោយចេតនាក៏



១២៤៨

ពុំមានភស្តុតាងណាបញ្ជាក់ឡើយ គប្បីពិចារណាសំរេចតាមច្បាប់។

៦-អំពើ និង សកម្មភាពរបស់ជនជាប់ចោទឈ្មោះNWATU [redacted] មានធាតុផ្សំគ្រាប់គ្រាន់ ដើម្បីចោទប្រកាន់ពីបទប្លន់ ធ្វើឲ្យខូចខាតដោយចេតនា និង បទចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានច្បាប់អនុញ្ញាត ដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។

៧-មានភស្តុតាង និង ពិរុទ្ធភាពគ្រាប់គ្រាន់លើឈ្មោះ NWATU [redacted] ពីបទប្លន់.បទធ្វើឲ្យខូចខាតដោយចេតនា និង បទចូលមកព្រះរាជាណាចក្រកម្ពុជាដោយគ្មានច្បាប់អនុញ្ញាត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០១-៣-២០១០។

៨-ជនជាប់ចោទទើបប្រព្រឹត្តបទល្មើសជាលើកទី១ ហើយព្យសនកម្មពុំមានលក្ខណៈធ្ងន់ធ្ងរទេ គប្បីតុលាការពិចារណាអំពីស្ថានសំរាលទោសតាមច្បាប់។

៩-សាលក្រមព្រហ្មទណ្ឌលេខ៩០ក្រ២យ/២៤-៨-២០១០របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតំកល់ទុកជាបានការ លើកលែងតែចំណុចទី១ គប្បីសំរេចឲ្យជនជាប់ចោទរួចផុតពីបទចោទ ប្រើប្រាស់គ្រឿងញៀន និង គួរបន្ធូរបន្ថយទណ្ឌកម្មពីចំនួន០៦ឆ្នាំមកត្រឹម០៥ឆ្នាំ(ប្រាំឆ្នាំ)វិញ តាមមាត្រា៩៣ និង មាត្រា៩៤នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

**១**-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-៨-២០១០របស់លោក [redacted] សាវុឌ្ឍី ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ NWATU [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

**២**-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៩០ក្រ២យ/២៤-៨-២០១០របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ត្រូវកែប្រែជាថ្មីថា៖

ក/កែប្រែទណ្ឌកម្មពន្ធនាគារលើឈ្មោះNWATU [redacted] មកចំនួន០៥ឆ្នាំវិញ។

ខ/ឲ្យជនជាប់ចោទរូបនេះរួចផុតពីបទ ប្រើប្រាស់គ្រឿងញៀន។

គ/ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

**៣**-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

**៤**-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០១-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ និង ជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមត្រឹមត្រូវតាមច្បាប់ ។**

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted]

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី 15 ខែ 11 ឆ្នាំ២០១៤

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]